វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១០ លេខ ០៥

## ការពង្រឹងវិស័យសំខាន់ៗដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា៖ វិស័យទេសចរណ៍[1]

"ទេសចរណ៍ ជាវិស័យអាទិភាពមួយជួយរួមចំណែកដល់ ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ការបង្កើតការងារ និងការបង្កើតប្រាក់ចំណូល ។ ប៉ុន្តែវិស័យនេះ ងាយរងការប៉ះទង្គិចពីហានិភ័យទាំងខាងក្នុងប្រទេស និងខាងក្រៅប្រទេស... ហានិភ័យទាំងនោះ អាចប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ ហើយជះឥទ្ធិពលភ្លាមៗ និងយូរអង្វែងទៅលើសេដ្ឋកិច្ច ។"

*លោក ហ៊ិយ ភីរក្ស អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍*

"ទោះមាន ឬគ្មានវិបត្តិ បញ្ហានៅតែមានចោទ"

*លោក លូ ម៉េង ប្រធានសមាគមសណ្ឋាគារកម្ពុជា*

### ទេសចរណ៍៖ ភាពធន់ទ្រាំនឹងវិបត្តិ

ទេសចរណ៍ ជាវិស័យជំរុញកំណើនមួយរបស់កម្ពុជា ដែលបានជួយលើកកំពស់កំរិតជីវភាព និងកាត់បន្ថយភាពក្រីក្រ ។ វាជាប្រភពចំណូលមួយដ៏សំខាន់ សំរាប់ជំរុញកំណើនសេដ្ឋកិច្ច និងជួយទ្រទ្រង់ជញ្ជីងពាណិជ្ជកម្ម ។ វិស័យទេសចរណ៍លើកកំពស់កិត្យានុភាពជាតិ និងពង្រឹងចំណងមេត្រីភាព សាមគ្គីភាព សហប្រតិបត្តិការ ព្រមទាំងសមាហរណកម្មអន្តរជាតិ និងក្នុងតំបន់ ។ បើសិនមានការគ្រប់គ្រងប្រកបដោយទំនួលខុសត្រូវខ្ពស់ វិស័យនេះក៏អាចរួមចំណែកជួយថែរក្សាធនធានវប្បធម៌ និងធម្មជាតិផងដែរ ។ ប៉ុន្តែទេសចរណ៍ងាយរងការប៉ះពាល់ពីហានិភ័យទាំងខាងក្នុងប្រទេស និងខាងក្រៅប្រទេស ដូចជា ភាពមិនទៀងទាត់នៃសេដ្ឋកិច្ច និងនយោបាយ និងគ្រោះធម្មជាតិជាដើម ។ ហានិភ័យទាំងនេះអាចបង្កការខូចខាតធ្ងន់ធ្ងរដល់ទេសចរណ៍ ដែលអាចជះឥទ្ធិពលធ្ងន់ធ្ងរ ទៅលើចំណូលគ្រួសារ ការវិនិយោគ និងសេដ្ឋកិច្ច ។

ភាពងាយរងគ្រោះនៃវិស័យទេសចរណ៍ ដោយសារអស្ថិរភាពខាងក្រៅប្រទេស អាចមើលឃើញច្បាស់ក្នុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ដែលបច្ចុប្បន្នប្រទេសនានាក្នុងពិភពលោក ទើបតែរើបឡើងវិញខ្លះៗប៉ុណ្ណោះ ។ ការរួមចុះសេដ្ឋកិច្ចក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសផ្សេងទៀត ធ្វើឲ្យចំណូលធ្លាក់ចុះ ហើយអត្រាគ្មានការងារធ្វើកើនឡើង ។ ចំណាយលើការធ្វើដំណើរអន្តរជាតិ និងទេសចរណ៍បានធ្លាក់ចុះ ដោយសារមនុស្សជាច្រើនកាន់តែតឹងតែងជីវភាព ។

វិស័យទេសចរណ៍កម្ពុជា បានរងការប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចសាកល ហើយក្នុងពេលជាមួយគ្នា ក៏ត្រូវប៉ះទង្គិចដោយសារវិបត្តិនយោបាយនៅប្រទេសថៃ ការប្រឈមមុខគ្នានៅព្រំដែនកម្ពុជា-ថៃ និងការឆ្លងរាលដាលជំងឺផ្តាសសាយ H1N1 ។ នៅចុងឆ្នាំ២០០៨ ចំនួនភ្ញៀវអន្តរជាតិមកដល់បានធ្លាក់ចុះអស់ ៩% ធៀបនឹងកាលពីមួយឆ្នាំមុន (ក្រាហ្វិក ១) ។ សូម្បីនៅរដូវមមាញឹកបំផុត អត្រាស្នាក់នៅសណ្ឋាគារមានត្រឹម ១០-២០% ប៉ុណ្ណោះ ។ សណ្ឋាគារដែលបិទទ្វារឈប់ដំណើរការមានតិចទេ ប៉ុន្តែមានអាជីវកម្មជាច្រើន

---

១ សង្ខេបចក្ខុវិស័យលេខ ៥ បូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗ នៅវគ្គទី ៣ខ (ii) នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ ។ វាគ្មិនក្នុងវគ្គនេះ រួមមាន លោក ហ៊ិយ ភីរក្ស អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍ និង លោក លូ ម៉េង ប្រធានសមាគមសណ្ឋាគារកម្ពុជា ។

ត្រូវបញ្ឈប់ដំណើរការនៃផ្នែកខ្លះរបស់ខ្លួន ។ ទោះយ៉ាងនេះក្តី វិស័យទេសចរណ៍ក៏នៅតែធន់ទ្រាំបានខ្លះដែរ ព្រោះថាក្នុងឆ្នាំ ២០០៨ វាកើនបាន ៥,៥% ធៀបនឹងឆ្នាំ២០០៧ ដោយមានភ្ញៀវទេសចរណ៍អន្តរជាតិមកដល់សរុបជាង ២,១លាននាក់ ។ សកម្មភាពទេសចរណ៍មកពីទីផ្សារខ្លះបានធ្លាក់ចុះ (ភ្ញៀវទេសចរមកពីកូរ៉េខាងត្បូង ធ្លាក់ចុះ ១៩%) ប៉ុន្តែសកម្មភាពទេសចរណ៍មកពីទីផ្សារខ្លះទៀតកើនឡើង (ភ្ញៀវទេសចរមកពីវៀតណាម កើន ៦៧%) ។ ដោយសារថវិកាមានកំរិតរដ្ឋាភិបាលតែឯង ពិបាកទប់ទល់នឹងឥទ្ធិពលនៃវិបត្តិសាកល និងកត្តាផ្សេងទៀត ដែលប៉ះពាល់ដល់វិស័យទេសចរណ៍ណាស់ ប៉ុន្តែក៏នៅតែអាចដាក់អនុវត្តវិធានការមួយចំនួន ដើម្បីជួយសំរាលការលំបាកក្នុងវិស័យទេសចរណ៍ដែរ ។ វិធានការទាំងនេះមានជាអាទិ៍ ការបង្កើតក្រុមហ៊ុនអាកាសចរណ៍ជាតិឈ្មោះ ខេមបូឌាអង្គរអ៊ែរ និងសកម្មភាពឃោសនាផ្សព្វផ្សាយផ្សេងៗរបស់ក្រសួងទេសចរណ៍ ដើម្បីបង្កើនលំហូរចូលភ្ញៀវទេសចរ ។ ដោយមានជំនួយពីវិស័យឯកជន និងសហគមន៍អ្នកផ្តល់ជំនួយក្នុងឆ្នាំ២០០៩ វិស័យទេសចរណ៍នៅតែអាចសំរេចបានកំណើន ១,៧% ។ សញ្ញារើបឡើងវិញ អាចពិនិត្យឃើញជាលើកដំបូងនៅដើមឆមាសទី២ ឆ្នាំមុន នៅពេលដែលភ្ញៀវទេសចរអន្តរជាតិ ចាប់មានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំជាវិជ្ជមានដល់ ៨% នៅខែមិថុនា (ក្រាហ្វិក ១) ។ ធនាគារនានា ក៏ចាប់ដំណើរការឲ្យខ្ចីប្រាក់ឡើងវិញ ហើយវេទិកាទេសចរណ៍អាស៊ានក៏បានព្យាករណ៍សុទិដ្ឋិនិយមដែរ ។ ភ្ញៀវទេសចរមកកម្ពុជា រំពឹងថានឹងកើនពី ៣-៧% ក្នុងឆ្នាំ ២០១០ ធៀបនឹងឆ្នាំ២០០៩ ។ ត្រឹមខែមករា ២០១០ ភ្ញៀវទេសចរមកដល់កម្ពុជា មានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ដល់ទៅ ៥% ។

## ទេសចរណ៍៖ ទោះមាន ឬគ្មានវិបត្តិក្តី

ទោះមាន ឬគ្មានវិបត្តិក្តី វិស័យទេសចរណ៍កម្ពុជានៅតែត្រូវប្រឈមមុខនឹងបញ្ហាធំៗ ដែលគំរាមកំហែងដល់ចីរភាពនៃកំណើនរបស់វា ហើយបញ្ហាចំបងគេ គឺកង្វះពិពិធកម្មក្នុងការផ្តល់សេវាកម្ម និងការទាក់ទាញភ្ញៀវទេសចរ ។ ភាពប្រកួតប្រជែងនៃវិស័យទេសចរណ៍ ក៏ត្រូវរាំងស្ទះដោយបញ្ហាចោទក្នុងការសម្របសម្រួលការធ្វើដំណើរ ថ្លៃដ៏ខ្ពស់នៃសំបុត្រយន្តហោះមកកម្ពុជា ការឃោសនាផ្សព្វផ្សាយមិនគ្រប់គ្រាន់ និងចំណាយខ្ពស់ ក្នុងដំណើរស្វែងយល់ពីប្រទេសកម្ពុជាដែលឆ្លុះបញ្ចាំងមួយចំណែក ពីបន្ទុកចំណាយដ៏ខ្ពស់របស់ប្រតិបត្តិករទេសចរណ៍ ។ សរុបមក វិស័យទេសចរណ៍កម្ពុជាមានកម្លាំងប្រកួតប្រជែងខ្សោយជាងប្រទេសជិតខាងគឺ ថៃ និង វៀតណាម ។ នៅឆ្នាំ២០០៩ សន្ទស្សន៍ភាពប្រកួតប្រជែងខាងវិស័យទេសចរណ៍ និងការធ្វើដំណើរ បានធ្វើចំណាត់ថ្នាក់

ក្រាហ្វិក ១៖ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា (%)




ប្រភព៖ ក្រសួងទេសចរណ៍

ប្រទេសកម្ពុជាឲ្យជាប់លេខ ១១៨ ក្នុងចំណោម ១៣៣ ប្រទេស ស្របពេលដែល ថៃ ជាប់លេខ ៣៩ និង វៀតណាម ជាប់លេខ ៨៩ ។

បញ្ហាប្រឈមសំខាន់មួយ គឺការធ្វើឲ្យកម្ពុជាក្លាយជាប្រទេសគោលដៅតែម្តង និងមិនមែនជាដំណើរបន្តពីប្រទេសផ្សេងនោះទេ ។ ការផ្តោតទាំងលើបរិមាណ និងគុណភាពនៃទេសចរណ៍ នឹងពង្រឹងសមត្ថភាពវិស័យនេះ ដើម្បីទ្រាំទ្រនឹងការប៉ះទង្គិចទៅថ្ងៃអនាគត ។ មានសំណួរពិបាកឆ្លើយមួយចំនួន កំពុងចោទឡើងលើវិស័យទេសចរណ៍ ។ តើភាពល្អបរិសុទ្ធនៃតំបន់វប្បធម៌អាចថែរក្សាបានតាមវិធីណា ? តើចំនួនថ្ងៃស្នាក់នៅជាមធ្យមរបស់ភ្ញៀវទេសចរ អាចនឹងបង្កើនឡើងតាមវិធីណា ? តើធ្វើយ៉ាងណាឲ្យភ្ញៀវចូលមកទស្សនាប្រទេសកម្ពុជាម្តងហើយម្តងទៀត ? តើធ្វើយ៉ាងណាអាចទាក់ទាញភ្ញៀវអ្នកចាយប្រាក់ច្រើន ឲ្យមកទស្សនាកម្ពុជាកាន់តែច្រើននាក់ ? តើធ្វើយ៉ាងណាអាចទាក់ទាញការប្រជុំដំណើរកំសាន្តលើកទឹកចិត្ត សន្និសីទ និងការតាំងពិពណ៌ (MICE) ឲ្យមករៀបចំនៅកម្ពុជាកាន់តែច្រើនឡើង ?

ដើម្បីដោះស្រាយបញ្ហាប្រឈម និងសំណួរទាំងនេះ ត្រូវអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រធំៗ ៥ (ដែលត្រូវមានវិធានការជាក់លាក់សំរាប់គាំទ្រមួយចំនួនទៀត) ដូចតទៅ៖ (១) កែលំអការសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (២) កាត់បន្ថយចំណាយធ្វើដំណើរ និងទស្សនកិច្ច (៣) ធ្វើពិពិធកម្មសកម្មភាពទាក់ទាញទេសចរនិងបង្កើនគុណភាពផលិតផលនិងសេវាទេសចរណ៍ (៤) ពង្រីកទីផ្សារទេសចរណ៍ និង (៥) បង្កើនសកម្មភាពម៉ាឃីតទីង ។

យុទ្ធសាស្ត្រដំបូង គឺការសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលអាចអនុវត្តបានជោគជ័យលុះត្រាតែមានសហប្រតិបត្តិការជាមួយប្រទេសជិតខាង ។ ជាពិសេសការងារនេះត្រូវមាន៖ ការអនុវត្តកិច្ចព្រមព្រៀងស្តីពីទេសចរណ៍ឆ្លងកាត់ព្រំដែន ការបង្កើនចំនួនយានយន្តដឹកទេសចរឆ្លងកាត់ព្រំដែន ការយល់ព្រមឲ្យប្រើលិខិតអនុញ្ញាត

ក្រាហ្វិក ២៖ យុទ្ធសាស្ត្រទេសចរណ៍




ឆ្លងកាត់ព្រំដែន ឬឯកសារសាមញ្ញៗផ្សេងទៀតសំរាប់ភ្ញៀវទេសចរឆ្លងកាត់ព្រំដែន ការបញ្ចុះថ្លៃទិដ្ឋាការយ៉ាងតិច ៥០% សំរាប់ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក ដើម្បីជំរុញទេសចរណ៍ក្នុងតំបន់ ការសាកល្បងមិនយកថ្លៃទិដ្ឋាការសំរាប់ទេសចរមកពី ជប៉ុន ចិន និងកូរ៉េខាងត្បូង ការកាត់បន្ថយចំណាយលើសេវាធ្វើដំណើរមួយចំនួន ឬការបូកបញ្ចូលចំណាយនេះក្នុងសំបុត្រយន្តហោះ ការពង្រីកគោលនយោបាយបើកចំហជើងមេឃ ទៅអនុវត្តលើផ្លូវហោះហើរខេត្តសៀមរាប-ក្រុងបាងកក ការបង្កើនជើងហោះហើរត្រង់ទៅកាន់ខេត្តសៀមរាប ភ្នំពេញ និងខេត្តព្រះសីហនុ និងការហោះហើរត្រង់ពីខេត្តសៀមរាបទៅខេត្តព្រះសីហនុ ការកែលំអសេវាក្រុមហ៊ុនអាកាសចរណ៍ជាតិ ការពង្រឹងគុណភាព សេវាដឹកជញ្ជូនភ្ញៀវទេសចរពីព្រំដែន ការកែលំអការគ្រប់គ្រងនិងការបង្កើតសមាគមក្រុមហ៊ុនដឹកជញ្ជូន ការកែលំអសេវាព័ត៌មាននិងបដិសណ្ឋារកិច្ចនៅច្រកព្រំដែន និងការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ដល់ប្រជាជននៅមូលដ្ឋាន ដើម្បីឲ្យពួកគេអាចជួយជំរុញវិស័យទេសចរណ៍ ។

ថ្លៃធ្វើដំណើរកំរិតខ្ពស់ ទាំងជាផ្លូវការ និងមិនផ្លូវការ ជាឧបសគ្គចំបងក្នុងការទាក់ទាញទេសចរ ជាពិសេសភ្ញៀវចេញចូលញឹកញាប់ និងភ្ញៀវស្នាក់នៅរយៈពេលវែង ។ យុទ្ធសាស្ត្រទីពីរ គឺការបញ្ចុះចំណាយទាំងនេះ ដែលត្រូវមានការកាត់បន្ថយ៖ ថ្លៃកញ្ចប់ទស្សនកិច្ច ថ្លៃទិដ្ឋាការ (ដូចបានលើកឡើងហើយ) ថ្លៃសំបុត្រចូលទស្សនា និងថ្លៃផ្សេងៗទៀតនៅតាមរមណីយដ្ឋានទេសចរណ៍ និងថ្លៃស្នាក់នៅម្ហូបអាហារ និងមធ្យោបាយធ្វើដំណើរ ។

ទេសចរណ៍វប្បធម៌ និងប្រាសាទអង្គរវត្ត ជាសសរទ្រូងនៃវិស័យទេសចរណ៍កម្ពុជា ។ការជំរុញទេសចរណ៍ប្រភេទនេះជាការល្អ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេសំរាប់រក្សាចីរភាពក្នុងវិស័យទេសចរណ៍ ។ យុទ្ធសាស្ត្រទីបី គឺពិពិធកម្មសកម្មភាពទាក់ទាញទេសចរ និងការបង្កើនគុណភាពផលិតផល និងសេវាទេសចរណ៍ ដែលត្រូវមាន៖ ការជំរុញអេកូទេសចរណ៍ជាពិសេសនៅតំបន់ឆ្នេរ ការថែរក្សាធនធានវប្បធម៌ និងធម្មជាតិ ការកែប្រែគោលដៅទេសចរណ៍ពីទេសចរណ៍មហាជន ទៅជាទេសចរណ៍ប្រណិត ការលើកកំពស់ការអភិវឌ្ឍទីក្រុង និងការគ្រប់គ្រងទឹកនិងកាកសំណល់នៅតំបន់ទេសចរណ៍ ការពង្រឹងសន្តិសុខនិងវិន័យនគរបាលទេសចរណ៍ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ដើម្បីធានាសុវត្ថិភាពភ្ញៀវ និងទំនុកចិត្តរបស់ពួកគេលើសន្តិសុខនៅកម្ពុជា ការបង្កើតសាលាបង្រៀនវិជ្ជាចំអិនអាហារថ្នាក់លេខមួយ ការគ្រប់គ្រងសណ្ឋាគារនិងភោជនីយដ្ឋាន និងវិជ្ជាជីវៈពាក់ព័ន្ធដទៃទៀត ការបណ្តុះបណ្តាលបន្ថែមផ្នែកបដិសណ្ឋារកិច្ច ការណែនាំ និងដាក់អនុវត្តស្តង់ដារទេសចរណ៍ស្របតាមច្បាប់ទេសចរណ៍ និងការលើកកំពស់អនាម័យស្របតាមពាក្យស្លោក "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" ។

ទោះជាទេសចរណ៍មកពីទីផ្សារអាស៊ីជាប្រពៃណី មានការធ្លាក់ចុះ ប៉ុន្តែទេសចរណ៍មកពីទីផ្សារអាស៊ីថ្មីៗទៀត និងមកពីតំបន់អឺរ៉ុបនៅតែខ្លាំងក្លា ។ដូច្នេះ យុទ្ធសាស្ត្រទីបួន គឺការស្វែងរកប្រភពទេសចរឲ្យបានច្រើនប្រទេសថែមទៀត ដោយត្រូវធ្វើការឃោសនាផ្សព្វផ្សាយ ឲ្យប្រទេសកម្ពុជាក្លាយជាគោលដៅនៃដំណើរកំសាន្ត នៅក្នុងទីផ្សារនៃប្រទេសជាសមាជិកអាស៊ាន តំបន់អឺរ៉ុប ប្រទេសរុស្ស៊ី និងទីផ្សារថ្មីៗទៀត ។ គួរកំណត់អនិកជនខ្មែរនៅបរទេស ជាទីផ្សារទេសចរណ៍មួយដែរ ព្រមទាំងប្រឹងជំរុញទេសចរណ៍ក្នុងស្រុកថែមទៀត ។

យុទ្ធសាស្ត្រទីប្រាំ ការបង្កើនសកម្មភាពម៉ាឃីតទីងទាមទារនូវ៖ ការធ្វើទស្សនកិច្ចណែនាំ (FAM trips) ឲ្យបានកាន់តែច្រើន ការឃោសនាផ្សព្វផ្សាយក្នុងទីផ្សារគោលដៅជាក់លាក់ក្នុងតំបន់ ការរៀបចំសកម្មភាពទេសចរណ៍ផ្សេងៗនៅតាមព្រំដែន ការជំរុញផ្សព្វផ្សាយសហគ្រាសនានាដែលអាចទទួលបានពានរង្វាន់ខាងវិស័យទេសចរណ៍ ឬការទទួលស្គាល់ជាអន្តរជាតិ ការបញ្ជូនតំណាងវិស័យទេសចរណ៍ទៅប្រទេសឯទៀតៗដើម្បីផ្សព្វផ្សាយព័ត៌មាន ការផ្សាយពាណិជ្ជកម្មតាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ មានទាំងវែបសាយផង និងយុទ្ធនាការទាក់ទាញដោយប្រើពាក្យស្លោក "កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ" ការបង្កើតក្រុមប្រឹក្សាខាងផ្សព្វផ្សាយ និងម៉ាឃីតទីង ដោយមានថវិកាលៃចែកពីរដ្ឋាភិបាលសំរាប់ជំរុញការផ្សព្វផ្សាយ និងការរួមសហការ ជាមួយទីភ្នាក់ងារផ្សព្វផ្សាយអាជីពនៅក្នុងប្រទេសគោលដៅ ។

អារម្មណ៍សុទិដ្ឋិនិយមពីអនាគតនៃវិស័យទេសចរណ៍កម្ពុជា នៅតែមានដដែល ទោះជាមានបញ្ហាប្រឈមច្រើនយ៉ាងណាក្តី ។ សម្រស់ល្អវិសេសទាក់ទាញភ្ញៀវរបស់ប្រទេសកម្ពុជា ពិតជានឹងជួយពង្រឹងវិស័យទេសចរណ៍ ។

## សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ (ADR) ២០០៩-១០

*ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI*

ខ្លឹមសារសំខាន់ៗនៃសង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ លើកទី៥ នេះ មានដូចតទៅ៖

- សេចក្តីផ្តើម
- កម្ពុជានៅក្រោមឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាកល
- សន្តិសុខស្បៀងនៅកម្ពុជាក្នុងពេលមានវិបត្តិស្បៀង និងវិបត្តិសេដ្ឋកិច្ច
- តើក្រុមគ្រួសារនៅជនបទកម្ពុជា ទប់ទល់យ៉ាងណា ចំពោះការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ?
- ការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និងការគ្រប់គ្រង មិនផ្លូវការលើហានិភ័យ ក្នុងអំឡុងពេលវិបត្តិ សេដ្ឋកិច្ចនៅកម្ពុជា
- របៀបចាត់ចែងការងាររបស់អ្នកគ្រប់គ្រងក្នុងវិស័យ សុខាភិបាល
- ស្វែងរកច្រកដ៏ល្អ សំរាប់បង្កើនទំនាក់ទំនងរវាងសង្គម ស៊ីវិល និងសមាជិកសភានៅកម្ពុជា




- វិនិយោគទុនចិន នៅក្នុងប្រទេសកម្ពុជា
- សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម និងកំណើន នៅក្នុងប្រទេស៖ ករណីសិក្សាក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុ
- ការស្វែងយល់ពីសេដ្ឋកិច្ចនយោបាយនៃសមាហរណកម្ម ក្នុងមហាអនុតំបន់មេគង្គ
- ការចូលរួមរបស់កសិករអ្នកប្រើប្រាស់ទឹក និងជោគជ័យ នៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រដោយកសិករ៖ ករណី សិក្សានៅសហគមន៍កសិករអ្នកប្រើប្រាស់ទឹក អូរត្រែង ខេត្តកំពង់ស្ពឺ

ឯកសារ ADR ២០០៩-១០ នេះ ក៏ដូចជា ADR ដទៃទៀតដែរ មានចុះព័ត៌មានសំខាន់ៗ ទាក់ទងនឹងបញ្ហាដែលកម្ពុជាកំពុង ប្រឈមមុខក្នុងពេលថ្មីៗនេះ ។ ឯកសារ ADR នេះ មាន បោះពុម្ពផ្សាយ អត្ថបទពេញលេញជាភាសាអង់គ្លេស និង អត្ថបទសង្ខេបជាភាសាខ្មែរ ។




*ADR05 ជាភាសាខ្មែរ*

*លក់ទៅបរទេស៖ $៩,៥០ ក្នុងស្រុក៖ ៨.០០០៛*

*ADR05 ជាភាសាអង់គ្លេស*

*លក់ទៅបរទេស៖ $៣៧,០០ ក្នុងស្រុក៖ $២០,០០*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@wicam.com.kh, website: http://www.cdri.org.kh